ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

ធ្នូ ២០០៥ / December 2005

**កញ្ញា អ៊ុច ចំន្ទតារានី / Ms. Ouch Chandarany**

**លោកស្រី ប៉ុន ដូរីណា / Ms. Pon Dorina**

**លោក ហ៊ីង វុត្ថា / Mr. Hing Vutha**

**លោក ភឹម រុនស៊ីណារិទ្ធិ / Mr. Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ**

**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅខែសីហា CDC បានអនុម័តគំរោងវិនិយោគឯកជន (បូកទាំងការពង្រីកគំរោងមានស្រាប់ផង) មានតំលៃគិតជាទ្រព្យសកម្មជាប់លាប់បានចុះបញ្ជី ២៤៥,៦លានដុល្លារ (៦៣លានដុល្លារកាលពីខែកក្កដា) ក្នុងនេះជាង ៧០% ជាវិនិយោគលើរោងចក្រស៊ីម៉ង់ត៍នៅកំពត (១៨០,៨លានដុល្លារ) ។ ក្នុង ៨ ខែដើមឆ្នាំ២០០៥ វិនិយោគឯកជនបានអនុម័តមាន ៨៨០,២លានដុល្លារ ។

The registered fixed assets of private investment projects approved by the CDC, including expansion projects, amounted to $245.6 million in August, up from $63 million in July. Investment in a cement factory in Kampot province accounted for over 70 percent ($180.8 million) of total approvals. The cement factory is 75 percent Cambodian and 25 percent Thai. During the first eight months of 2005, total private investment approvals reached $880.2 million, compared to about $240.3 million during the same period last year.

**Private Investment by Sectors**
(US$ million)




*Note: Latest data available are for August 2005.*
*(Including expansion project approvals).*
Source: Council for the Development of Cambodia

នៅត្រីមាសទី៣ ២០០៥ ភ្ញៀវបរទេសចូលមកកម្ពុជាមាន ៣២៣.២១៧ នាក់រឺ ១០% ច្រើនជាងត្រីមាសមុនរឺ ៤២% ច្រើនជាងត្រីមាសទី៣ឆ្នាំមុន ។ ក្នុងនេះភ្ញៀវមកដល់តាមយន្តហោះកើន ៤១% ដល់ ២០២.៨៣៣នាក់ និងតាមផ្លូវគោកនិងផ្លូវទឹក កើន ៤៣% ដល់ ១២០.៣៨៤នាក់ ។ ពីខែមករា ដល់ កញ្ញា ២០០៥ ភ្ញៀវបរទេសមកដល់មានសរុប ៩៩៧.៥៧៧នាក់ រឺកើន ៤៧,៥% ពីកំរិត ៦៧៦.៣៧០នាក់ ក្នុងរយៈពេលដូចគ្នាឆ្នាំ២០០៤ ។

The number of foreign visitors entering Cambodia in third quarter 2005 totalled 323,217, 10 percent more than in the preceding quarter. Compared to the third quarter of last year, foreign arrivals rose by nearly 42 percent. Arrivals by air increased by 41 percent to 202,833 persons, and arrivals by land and boat went up by about 43 percent to 120,384 persons. From January to September 2005, the number of foreign visitor arrivals totalled 997,577, an increase of 47.5 percent from 676,370 persons in the same period during 2004.

**Foreign Visitor Arrivals to Cambodia by Air, Land and Boat**
(thousand persons)




*Note: Visitor arrivals by land and boat in Q4-04 and 2005 include visitors to Preah Vihear.*
Source: Ministry of Tourism

នៅភ្នំពេញ គំរោងសំនង់ដែលបានទទួលការអនុមតិនៅត្រីមាសទី៣ ២០០៥ មាន ៧៦,៥លានដុល្លារ រឺថយចុះ ២៦,៧% ធៀបនឹងត្រីមាសទី២ ប៉ុន្តែថយចុះតែ ១,៨% ប៉ុណ្ណោះបើធៀបនឹងត្រីមាសទី៣ ២០០៤ ។ ក្នុងនេះ សំណង់ផ្ទះល្វែងដែលជាចំនែកធំជាងគេ ថយចុះ ៦,៨% ដល់ ៤១,៣លានដុល្លារ រីឯសកម្មភាពសាងសង់ផ្សេងៗថយចុះ ៣៨,៧% ដល់ ១៦លាន ដុល្លារ ប៉ុន្តែសំណង់ភូមិគ្រឹះ និងផ្ទះ កើនជាង ២៥០% ដល់ ១៩,២លានដុល្លារ ។

In Phnom Penh, construction projects worth $76.5 million were approved in the third quarter of 2005, down 26.7 percent from the second quarter. However, the decrease was only 1.8 percent when compared to third quarter 2004. Flat construction approvals, which continued to make up the largest amount of the construction projects, declined by 6.8 percent to $41.3 million. Other activities showed a drop of 38.7 percent to $16 million. These declines were counterbalanced by villa and house constructions, which rose over two and a half times to $19.2 million.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for September 2005.*
Source: Department of Cadastre and Geography, Phnom Penh municipality.

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែវិច្ឆិកា ថ្លៃសាំង និងម៉ាស៊ូតនៅភ្នំពេញ សឹងគ្មានការប្រែប្រួលធៀបនឹងខែតុលា ថ្វីបើនៅចុងខែវាបានធ្លាក់ចុះបន្តិចក្តី ។ សាំងមានថ្លៃលក់ជាមធ្យម ៣.៧៦៨រៀល/លីត្រ រីឯ ម៉ាស៊ូតមានថ្លៃលក់ ២.៩៣២រៀល/លីត្រ ។

In November, the average prices of gasoline and diesel oil in Phnom Penh remained almost unchanged from October, although they declined slightly toward the end of the month. One litre of gasoline averaged around 3,768 riels, while diesel sold at 2,932 riels per litre.

## Prices of Gasoline and Diesel Oil in Phnom Penh




Sources: CDRI and National Institute of Statistics

នៅខែតុលា ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញកើនបន្តិចត្រឹម ០,០៤% ធៀបនឹងខែមុន ។ ឯសន្ទស្សន៍ថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ បន្តកើនឡើង ០,៩%ធៀបនឹងខែកញ្ញា ។ ម្យ៉ាងទៀត ថ្លៃម្ហូបអាហារថយចុះ ០,៣% ។ ធៀបនឹងខែតុលា ឆ្នាំមុន ថ្លៃទំនិញទូទៅកើនប្រហែល ៦,៤% ។

Overall consumer prices in Phnom Penh in October rose marginally, by 0.04 percent, from the preceding month. The price index of transportation and communication continued to increase, jumping by 0.9 percent over September. On the other hand, food prices dropped by 0.3 percent. Compared to October a year earlier, overall prices were about 6.4 percent higher.

## Consumer Price Index

(July–December 2000=100)




*Note: Latest data available are for October 2005.*
Source: National Institute of Statistics

អត្រាការប្រាក់មធ្យមលើប្រាក់បញ្ញើរយៈ ១២ខែ របស់ធនាគារពាណិជ្ជនៅកម្ពុជាគឺ ៣,៦៧% សំរាប់ដុល្លារ និង ៦,៦% សំរាប់ប្រាក់រៀល នៅចុងខែកញ្ញានេះ ។ ក្នុងនេះ FTB និង ACLEDA ផ្តល់ការប្រាក់ ៥% និង ៦% សំរាប់បញ្ញើ ១២ខែជាដុល្លារ និង ៦,៥% ដូចគ្នាសំរាប់បញ្ញើជារៀល រីឯ Canadia ផ្តល់ ៥% សំរាប់បញ្ញើជាដុល្លារ និង ៦% សំរាប់បញ្ញើជារៀល ។ អត្រាការប្រាក់លើបញ្ញើ ១២ខែ ជាដុល្លារនិងរៀល សឹងគ្មានប្រែប្រួលទេ សំរាប់ធនាគារធំៗទាំងបីនេះ បើធៀបនឹងកាលពីឆ្នាំមុន ។

The average interest rate on 12-month deposits provided by commercial banks in Cambodia was 3.67 percent for US dollars and 6.6 percent for riels at the end of September. The Foreign Trade Bank and ACLEDA Bank offered 5 percent and 6 percent respectively on 12-month dollar deposits, and the same rate of 6.5 percent for riel deposit. Canadia bank offered 5 percent for 12-month dollar deposits and 6 percent for riel deposits. The interest rates on 12-month dollar and riel deposits of these three major banks remained almost unchanged from last year.

## Interest Rate on 12-Month Deposits

(As of September 2005)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់និងរូបិយវត្ថុ
# Exchange Rate and Monetary Developments

ប្រាក់រៀលបានឡើងថ្លៃទល់នឹងដុល្លារUS នៅទីផ្សារក្រុងភ្នំពេញនៅខែវិច្ឆិកា ដោយប្តូរបានជាមធ្យម ៤.១៨៤,៧រៀល/ដុល្លារ រឺឡើងថ្លៃ ០,៥% ធៀបនឹងខែមុន ប៉ុន្តែចុះថ្លៃ ៣,៧%ធៀបនឹងខែវិច្ឆិកា ឆ្នាំមុន ។

The riel appreciated against the US dollar in the Phnom Penh market in November, trading at an average rate of 4,184.7 riels/dollar. It was up by 0.5 percent compared to the preceding month, but depreciated by 3.7 percent from November last year.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

ក្រោយបានចុះថ្លៃអស់ ៧ខែជាប់គ្នា ប្រាក់រៀលបានឡើងថ្លៃទល់នឹងប្រាក់ដុងវៀតណាមនៅខែវិច្ឆិកា ដោយប្តូរបាន ២៦,៣រៀល/១០០ដុង ធៀបនឹង ២៦,៥រៀល/១០០ដុងនៅខែមុន ។ ដូចគ្នាដែរ ប្រាក់រៀលបានឡើងថ្លៃទល់នឹងប្រាក់បាតថៃ ក្រោយបានចុះថ្លៃអស់ ៣ខែជាប់គ្នា គឺ ១បាត ប្តូរបានប្រហែល ១០២រៀល នៅខែវិច្ឆិកា ធៀបនឹង ១០២,៨រៀល នៅខែកញ្ញា ។

After depreciating for seven consecutive months, the riel gained value against the Vietnamese dong in November, trading at 26.3 riels per 100 dongs, up from 26.5 riels per 100 dongs in the preceding month. Similarly, the riel appreciated against the Thai baht in November, after depreciating for three consecutive months. One baht was worth around 102 riels, compared to 102.8 riels in September.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

នៅខែកញ្ញា រូបិយវត្ថុទូទៅមាន ៤.៩៩៣,៨ពាន់លានរៀល រឺកើន ៤,៨% ធៀបនឹងខែសីហា ដែលកាលនោះវាបានថយចុះ ០,៤% ។ ដោយឡែកប្រាក់បញ្ញើជារូបិយវត្ថុបរទេសដែលមានចំណែកជាង ៧០% ក្នុងរូបិយវត្ថុទូទៅកើន ៣,៨% ដល់ប្រហែល ៨៦១,៤លានដុល្លារ (៣.៥៩៦,៣ពាន់លានរៀល) ។ ប្រាក់រៀលចរាចរនៅក្រៅធនាគារកើន ៤% ដល់ ១.២៣៥,១ពាន់លានរៀល និងប្រាក់រៀលជាប្រាក់បញ្ញើនៅធនាគារ កើន ១,៤% ដល់ ១៦២,៤ពាន់លានរៀល ។

Total liquidity in Cambodia amounted to 4,993.8 billion riels in September, a rise of 4.8 percent over August, when it had declined by 0.4 percent. Foreign currency deposits, which accounted for over 70 percent of total liquidity, grew by 3.8 percent to about $861.4 million (3,596.3 billion riels) from August to September. Riels circulating outside banks rose by 4 percent to 1,235.1 billion, and riels in bank deposits increased 1.4 percent, to 162.4 billion.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for September 2005.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅត្រីមាសទី៣ ២០០៥ ការនាំចេញរបស់កម្ពុជាមានសរុប ៧៣០លានដុល្លាររឺ ៤១.៨% ច្រើនជាងត្រីមាសទី២ ។ ក្នុងនេះ ៧០៩.៨លានដុល្លារ ជាផលិតផលសំលៀកបំពាក់ដែលនាំចេញទៅទីផ្សារពិភពលោក (ប្រហែល ៩០%ទៅ US និង EU) (កំនើន ៤២.៦%) ។ ការនាំចេញកៅស៊ូកើនឡើង ៥៩.៦% ដល់ ៩.៨លានដុល្លារ ឯត្រី និងអង្ករ ធ្លាក់ចុះ ៣៤.៤% ដល់ ០.៨ លានដុល្លារ និង ៣៥.៤% ដល់ ០.៧លានដុល្លាររៀងគ្នា ។

Cambodia's exports totalled $730 million in third quarter 2005, 41.8 percent more than in the second quarter. Cambodia exported $709.8 million in garment products to the world market (about 90 percent to US and EU), a 42.6 percent rise. Exports of rubber also jumped by 59.6 percent to $9.8 million, while exports of fish and rice went down by 34.4 percent to $0.8 million and by 35.4 percent to $0.7 million, resectively. Compared to the third quarter last year, Cambodia's total exports were up 9.2 percent.

## Cambodia's Main Exports
(US$ million)




*Note Latest data available are for September 2005.*
Source: Customs and Excise Department

នៅត្រីមាសទី៣ ការនាំចូលសំភារៈសំណង់ ដែក និងស៊ីម៉ងត៍ មានសរុប ៨២.៣ពាន់លានរៀលរឺ ២០% ច្រើនជាងត្រីមាសទី២ ។ការនាំចូលដែក កើនពី ១៨.១ពាន់លានដល់ ៣១ពាន់លាន(រ) ស៊ីម៉ង់ត៍កើន ១.៧% ដល់ ៥១.៣ ពាន់លានរៀល ឯបារីធ្លាក់ចុះ ១២.៤% ដល់ ៨៨.៣ពាន់លានរៀល ។ ធៀបនឹងត្រីមាសទី៣ ឆ្នាំមុន សំភារៈសំណង់នាំចូលកើន ៦៩.៥% ឯបារីនាំចូលធ្លាក់ចុះ ២.៣% ។

Imports of construction materials, steel and cement totalled 82.3 billion riels in the third quarter, 20 percent more than in the second quarter. Steel imports rose from 18.1 billion riels to 31 billion riels, while cement imports increased by 1.7 percent to 51.3 billion riels. Cigarette imports fell by 12.4 percent to 88.3 billion riels during this period. Compared to the third quarter last year, imports of construction materials climbed 69.5 percent, while imports of cigarettes dropped by 2.3 percent.

## Imports of Cigarette and Construction Materials
(billion riels)




*Note: Latest data available are for September 2005.*
*(Excluding public sector imports).*
Source: Customs and Excise Department

នៅត្រីមាសទី៣ ការនាំចូលម៉ាស៊ូត និងសាំង មាន ៩៨.៦ពាន់លានរៀល និង ៤១ពាន់លានរៀលរៀងគ្នា ។ ចំពោះម៉ាស៊ូត ថយចុះ ១.៨% ធៀបនឹងត្រីមាសទី២ និងចុះជិត ១០% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន រីឯសាំងកើនឡើង ៩.៧% ធៀបនឹងត្រីមាសទី២ និងកើន ៥៥.៥% ធៀបនឹង ត្រីមាសទី៣ ឆ្នាំមុន ។

Imports of diesel oil and gasoline in the third quarter were worth 98.6 billion riels and 41 billion riels, respectively. The value of diesel imports decreased by 1.8 percent from the second quarter and by nearly 10 percent from the same quarter last year, whereas gasoline imports rose by 9.7 percent over the second quarter and by 55.5 percent from the third quarter one year earlier.

## Imports of Petroleum Products (billion riels)




*Note: Latest data available are for September 2005.*
*(Excluding public sector imports).*
Source: Customs and Excise Department

# ប្រភពនិងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

នៅឆ្នាំ២០០៥ ក្រុងភ្នំពេញទទួលបាន ៣,៨ពាន់លានរៀលពីមូលនិធិឃុំ/សង្កាត់ រឺ ១១,៨% ច្រើនជាងឆ្នាំ២០០៤ ក្នុងនេះ មូលនិធិសំរាប់អភិវឌ្ឍន៏ កើន ១៣,៨% ដល់ ២,៦ពាន់លានរៀល រីឯ មូលនិធិសំរាប់រដ្ឋបាល ក៏កើន ៧,៥%ដែរ ដល់ប្រហែល ១,២ពាន់លានរៀល ។

In 2005, Phnom Penh obtained 3.8 billion riels from the commune/sangkat fund, 11.8 percent more than in 2004. Funds for development were 2.6 billion riels, a 13.8 percent increase. Administrative funds also grew by 7.5 percent to around 1.2 billion riels.

**2005 Commune/Sangkat Fund Allocation to Phnom Penh Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

ខេត្តកំពង់ស្ពឺដែលជួបគ្រោះរាំងស្ងួត ទទួល ៣,៧ពាន់លានរៀលពីមូលនិធិឃុំ/សង្កាត់នៅឆ្នាំ២០០៥ ធៀបនឹង ៣,៣ពាន់លានរៀលនៅឆ្នាំមុន ។ ក្នុងនេះមាន ២,៤ពាន់លានរៀលសំរាប់សកម្មភាពអភិវឌ្ឍន៏ (២,១ពាន់លានរៀលនៅឆ្នាំ២០០៤) និង ១,៣ពាន់លានរៀល សំរាប់ខាងរដ្ឋបាល (ប្រហែល ១,២ពាន់លានរៀល នៅឆ្នាំមុន) ។

Kompong Speu province, which is suffering from drought, received 3.7 billion riels from the commune/sangkat fund in 2005, compared to 3.3 billion riels the previous year. A total of 2.4 billion riels was promised for commune/sangkat development activities in 2005, up from 2.1 billion riels in 2004. The remaining 1.3 billion riels was for administration, rising from around 1.2 billion riels.

**2005 Commune/Sangkat Fund Allocation to Kompong Speu Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

មូលនិធិឃុំ/សង្កាត់ដែលផ្តល់អោយខេត្តកំពតនៅឆ្នាំ២០០៥ មានជាង ៣,៣ពាន់លានរៀល ធៀបនឹង ២,៩ពាន់លានរៀលនៅឆ្នាំ២០០៤ ក្នុងនេះ មូលនិធិសំរាប់អភិវឌ្ឍន៏មាន ២,៤ពាន់លានរៀល (កើន ១៩,៣%) និង សំរាប់ខាងរដ្ឋបាលមានជាង ០,៩ពាន់លានរៀល (កើន ៧,៤%) ។

Commune/sangkat funds allocated to Kampot province in 2005 were slightly over 3.3 billion riels, up from 2.9 billion riels in 2004. Funds for development were up by 19.3 percent to 2.4 billion riels, while administrative funds rose by 7.4 percent to over 0.9 billion riels.

**2005 Commune/Sangkat Fund Allocation to Kampot Province**




Source: Seila Task Force (January 2005), Annual Work Plan and Budget 2005

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅខែសីហា ប្រតិបត្តិការថវិកាចរន្តមានអតិរេក ៤៣,៩ពាន់លានរៀល ធៀបនឹងឱនភាព ៦២,៧ពាន់លានរៀលនៅខែមុន ។ ប៉ុន្តែអតិរេកនៅខែសីហានេះ មានកំរិត ១៦,៣% ទាបជាងក្នុងខែដូចគ្នាឆ្នាំ២០០៤ ។

In August, the current budget operated a surplus of 43.9 billion riels, compared to a deficit of 62.7 billion riels in the previous month. However, the current budget surplus in August was 16.3 percent lower than in the same month last year.

**Current Budget Operations**

(billion riels)




*Note: Provisional for 2004 and Jan–Aug 2005.*
Source: Ministry of Economy and Finance

ចំណាយថវិកាចរន្តនៅខែសីហា មានប្រហែល ១៨៨,១ពានលានរៀល រឺ ០,៧% ទាបជាងខែមុន ។ ផ្ទុយទៅវិញ ចំណូលចរន្ត កើនបាន ១៥,៤% បើធៀបនឹងខែសីហា ឆ្នាំ២០០៤ ។ ក្នុងចំណូលចរន្ត មាន ១០៥,៦ពាន់លានរៀល ជាចំណូលពន្ធនាំចូលនិងពន្ធនាំចេញ (កើន ២២% ធៀបនឹងកាលពីមួយឆ្នាំមុន) បន្ទាប់មកគឺពន្ធក្នុងស្រុក ដែលមាន ៤០,១ពាន់លានរៀល (កើន ១៥,២%) និងចំណូលមិនមែនពន្ធ ដែលមាន ៤២,៤ពាន់លានរៀល (សឹងស្មើគ្នានឹងឆ្នាំមុន) ។

Current budget revenue in August was approximately 188.1 billion riels, 0.7 percent less than in the preceding month. By contrast, current revenues rose by 15.4 percent from August 2004. A total of 105.6 billion riels was collected from import and export taxes, representing an increase of 22 percent, followed by a 15.2 percent rise to 40.1 billion riels in domestic tax. Non-tax revenues, 42.4 billion riels, were nearly the same as last year.

**Current Budget Revenue**

(billion riels)




*Note: Provisional for 2004 and Jan–Aug 2005.*
Source: Ministry of Economy and Finance

នៅខែសីហា ចំនាយថវិកាចរន្តមានចំនួន ១៤៤,២ពាន់លានរៀល រឺប្រហែល ៤៣% តិចជាងខែកក្កដា ប៉ុន្តែត្រូវជា ៣០,៤%ច្រើនជាងខែសីហាឆ្នាំមុន ។ ក្នុងនេះ ចំណាយខាងរដ្ឋបាលសេដ្ឋកិច្ច កើន ៥២% ដល់ ១៥ពាន់លានរៀល បន្ទាប់មកគឺចំណាយខាងសន្តិសុខ និងការពារជាតិ (កើន ៣០,៣% ដល់ ៣២,៤ពាន់លានរៀល) និងខាងរដ្ឋបាលទូទៅ (កើន ២៨,៦% ដល់ ៣៨,១ ពាន់លានរៀល) ។

Current budget spending of the government in August amounted to 144.2 billion riels, about a 43 percent reduction from July. Nevertheless, it increased by 30.4 percent from August 2004. During that period, economic administration spent 52 percent more, jumping to 15 billion riels, followed by defense and security (30.3 percent increase to 32.4 billion riels) and general administration spending (28.6 percent increase to 38.1 billion riels).

**Current Budget Expenditure**

(billion riels)




*Note: Provisional for 2004 and Jan–Aug 2005.*
Source: Ministry of Economy and Finance

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែកញ្ញា ការនាំចេញទំនិញរបស់ US ថយចុះ រីឯរបស់តំបន់អឺរ៉ូ និងជប៉ុន កើនឡើង ។ ការនាំចេញរបស់ US ថយចុះដល់ ៧៣,៤២ពាន់លានដុល្លារ រឺចុះ ៤% ធៀបនឹងខែមុន (៧៦,៦៧ពាន់លានដុល្លារ) ។ ការនាំចេញរបស់តំបន់អឺរ៉ូ កើន ៥% ពី ៨៣,៤០ ដល់ ៨៧,៧៤ពាន់លានដុល្លារ ហើយការនាំចេញរបស់ជប៉ុន កើន ១៥% ដល់ ៥៣,៧៧ពាន់លានដុល្លារ ។

In September, US goods exports decreased, while goods exports from the Euro-zone and Japan increased. US exports decreased by 4 percent from the previous month, from $76.67 billion to $73.42 billion. Exports of capital goods declined, while exports of vehicles, parts and engines, and consumer goods grew. Euro-zone exports in September increased by 5 percent, from $83.40 billion to $87.74 billion. Japan’s exports in September registered strong growth of 15 percent from the previous month to $53.77 billion.

### Goods Exports by the US, Eurozone and Japan
(US$ billion)




Sources: BEA, Eurostat and JETRO

នៅខែកញ្ញា ២០០៥ ការនាំចេញទំនិញពីកូរ៉េខាងត្បូង និងតៃវ៉ាន់កើនបន្តិចធៀបនឹងខែមុន គឺការនាំចេញពីកូរ៉េកើន ៥% ដល់ ២៤,៥៣ពាន់លានដុល្លារ (កើនគ្រប់ប្រភេទនាំចេញ លើកលែងតែភេសជ្ជៈ ថ្នាំជក់ និងខ្លាញ់រីប្រេងសត្វ/រុក្ខជាតិ ។ ការនាំចេញពីតៃវ៉ាន់ កើន ២% ដល់ ១៦,២ពាន់លានដុល្លារ ក្នុងនេះ ការនាំចេញម៉ាស៊ីន និងបរិក្ខារអេឡិចត្រូនិកកើនឡើង រីឯទំនិញដូចជា វាយនភណ្ឌ លោហៈសំខាន់ៗ បរិក្ខារដឹកជញ្ជូន បានថយចុះ ។

In September 2005, goods exports from South Korea and Taiwan increased slightly from the previous month. Korea’s exports in September rose 5 percent from the previous month to $24.53 billion. Except beverages and tobacco and animal and vegetable oils, all categories of exports grew. Taiwan’s exports in September registered a 2 percent increase to $16.2 billion. While exports of machinery and electronic equipment grew, categories such as textiles, basic metals, transportation equipment and precision instruments decreased.

### Goods Exports by South Korea and Taiwan
(US$ billion)




Sources: National statistics departments of Korea and Taiwan

នៅខែកញ្ញា ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,១៥ពាន់លានដុល្លារគឺថយពីកំរិត ២,៥៩ពាន់លាននៅខែសីហា ដោយសារការនាំចេញកើនបានតែ ២% ដល់ ១២,៥៤ពាន់លាន ប៉ុន្តែការនាំចូលកើន ៧% ដល់ ១០,៣៩ពាន់លាន ។ គ្រឿងអគ្គិសនី និងអេឡិចត្រូនិក គឺជាមុខទំនិញនាំចេញធំបំផុត បន្ទាប់មកគឺប្រេងឆា ផលិតផលធ្វើពីប្រេងឆា ប្រេងឆៅ ឈើ និងឧស្ម័នធម្មជាតិ ។

In September, Malaysia recorded a trade surplus of US$2.15 billion, compared with $2.59 billion in August. The slight decline in the trade surplus was due to an increase in exports of 2 percent or $0.27 billion and an increase in imports of 7 percent. Total exports and imports were valued at $12.54 billion and $10.39 billion respectively. Electrical & electronic products were Malaysia’s largest exports earners followed by palm oil and palm-oil-based products, crude petroleum, timber and liquefied natural gas.

### Malaysia's External Trade January–August 2005
(US$ billion)




Source: Malaysia External Trade Development Corporation

# ស្ថានភាពអតិផរណានៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅតំបន់អឺរ៉ូ កើន ២,៥% និងនៅ US កើន ៤,៧% ក្នុងរយៈមួយឆ្នាំដល់ចុងខែកញ្ញា ដែលបណ្តាលជាសំខាន់ពីថ្លៃថាមពលដែលស្ទុះឡើងបន្ទាប់ពីមានព្យុះ Katrina និង Rita ។ ឯនៅជប៉ុន សន្ទស្សន៍នេះថយចុះ 0,៣% តែថ្លៃទំនិញប្រើប្រាស់នៅថេរបើធៀបនឹងខែមុន និងបន្តមាននិន្នាការថយចុះបន្តិចធៀបនឹងឆ្នាំមុន ដែលបង្ហាញថា សេដ្ឋកិច្ចជប៉ុនស្ថិតក្នុងដំណាក់កាលមានបរិត្តផរណាខ្សោយ ។

The consumer price index edged up by 2.5 percent in the euro area and rose by 4.7 percent in the US in the year to September. This increase was largely due to a surge in energy prices in the aftermath of hurricanes Katrina and Rita. During the same period, the index declined by 0.3 percent in Japan. Japan's consumer prices were flat compared to the previous month but continued to show a slight declining trend against last year, implying that the Japanese economy is in a mild deflationary phase.

### Inflation in the US, Europe and Japan

(percentage change over previous year)




*Note: The latest data available are for September 2005.*
Sources: IMF and the *Economist* (19–25 November 2005)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង មានអត្រាកំនើនប្រចាំឆ្នាំ ១,៦% នៅខែកញ្ញា ដែលបណ្តាលជាសំខាន់ពីកំនើនថ្លៃឈ្នួលផ្ទះឯកជន និងកំនើនថ្លៃឧស្ម័ន ដែលផុសចេញពីការកែតំរូវលើបន្ទុកចំណាយលើបំរែបំរួលថ្លៃប្រេងឥន្ធនៈ ។ ក្នុងខែនេះដែរ ថ្លៃទំនិញប្រើប្រាស់មានអត្រាកំនើនប្រចាំឆ្នាំឡើងដល់ ២,៧% នៅចិន និងនៅត្រឹម 0,៩% នៅកូរ៉េខាងត្បូង ។

Hong Kong prices increased at an annual rate of 1.6 percent in September. This was mainly attributable to an increase in private housing rents and in the charge for town gas resulting from adjustment of the fuel cost variation charge. During the same period, the annual rate of consumer inflation accelerated to 2.7 percent in China and moderated to 0.9 percent in South Korea.

### Inflation in China, Hong Kong and South Korea

(percentage change over previous year)




*Note: The latest data available are for September 2005.*
Sources: IMF and the *Economist* (19–25 November 2005)

នៅខែកញ្ញា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅសិង្ហបុរី កើន 0,៦% ខ្ពស់ជាងខែដូចគ្នាឆ្នាំមុន ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបុរី រឿងនេះបណ្តាលជាសំខាន់ពីកំនើនថ្លៃម្ហូបអាហារ ការអប់រំ សំភារៈសិក្សា ចំណាយស្នាក់នៅ ថែទាំសុខភាព និងលំហែកំសាន្ត ។ នៅខែនេះដែរ ថ្លៃទំនិញកើនឡើង ៣,៤% នៅម៉ាឡេស៊ី និង ៦% នៅថៃ ។

Singapore’s consumer price index in September was 0.6 percent above the same month a year ago. According to the Department of Statistics of Singapore, this largely reflected higher costs of food, education and stationery, housing, health care and recreation. In the same period, prices rose by 3.4 percent in Malaysia and by 6 percent in Thailand.

### Inflation in Selected ASEAN Countries

(percentage change over previous year)




*Note: The latest data available are for September 2005.*
Sources: IMF and the *Economist* (19–25 November 2005)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែវិច្ឆិកា ដុល្លារអាមេរិកឡើងថ្លៃ ដោយ ១ដុល្លារ ប្តូរបាន ០,៨៥អឺរ៉ូ រឺ ១១៨,៣យ៉េន ។ គំលាតអត្រាការប្រាក់រវាងUS និងប្រទេសចំបងៗឯទៀត បានបន្តជួយទ្រទ្រង់ប្រាក់ដុល្លារ ។ កំលាំងជួយទ្រទ្រង់បន្ថែមមួយទៀត ផុសចេញពីតំរូវការពីបរទេសនូវទ្រព្យសកម្មផ្សេងៗនៅ US ដូចអាចពិនិត្យឃើញតាមកំនើនលំហូរទុនវិនិយោគចូលទៅ US ។

In November, the US dollar gained strength, trading at 0.85 against the euro and 118.3 against the yen. A widening interest rate differential in favour of the United States relative to major economies continued to support the dollar. Additional support came from buoyant foreign demand for US assets, as evidenced by a rise in portfolio investment flows into the US.

## Euro and Japanese Yen against US Dollar




*Note: Data are up to 28 November 2005.*
Source: Federal Reserve Bank of New York

នៅខែវិច្ឆិកា ២០០៥ ប្រាក់វ៉ុនកូរ៉េខាងត្បូងឡើងថ្លៃដល់ ១.០៤១,២៧វ៉ុន/ដុល្លារUS រឺឡើងថ្លៃ ០,៤%ទល់និងដុល្លារUS បើធៀបនឹងខែមុន ដោយសារទិន្នន័យផ្សេងៗបានបង្ហាញពីការរើបសេដ្ឋកិច្ចក្នុងស្រុកឡើងវិញ។ ក្នុងរយៈពេលដដែល ដុល្លារហុងកុងប្តូរបាន ៧,៧៥ដុល្លារហុងកុង/ដុល្លារUS ដោយសារមានកំលាំងទ្រទ្រង់ពី កំនើនសេដ្ឋកិច្ចធំជាងការរំពឹងទុកនៅត្រីមាសទី៣ ។

In November 2005, the South Korean won strengthened slightly against the US dollar, trading at 1,041.27, a 0.4 percent appreciation from a month earlier. The won's advance against the US dollar came as data pointed to a recovery in the domestic economy. During the same period, the Hong Kong dollar traded at 7.75 against its US counterpart. The Hong Kong dollar was underpinned by stronger than expected third quarter economic growth.

## South Korean Won and Hong Kong Dollar against US Dollar




*Note: Data are up to 28 November 2005.*
Source: Federal Reserve Bank of New York

នៅខែវិច្ឆិកា ដុល្លារសិង្ហបុរីចុះថ្លៃទល់នឹងដុល្លារUS ដោយ ១ដុល្លារUS ប្តូរបាន ១,៦៩៩ដុល្លារសិង្ហបុរី ធៀបនឹង ១,៦៩១ដុល្លារសិង្ហបុរីនៅខែតុលា ។ ប្រាក់បាតថៃចុះថ្លៃបន្តិចដែរទល់នឹងដុល្លារUS ដោយ ១ដុល្លារUS ប្តូរបាន ៤១,០៨បាត រឺចុះថ្លៃ ០,៥% ធៀបនឹងខែមុន ។ រូបិយវត្ថុប្រទេសអាស៊ីនានាបានចុះថ្លៃទល់និងដុល្លារUS ដោយសារទិន្នន័យជាច្រើនបង្ហាញពីកំនើនសេដ្ឋកិច្ចUS ខ្លាំង ដែលអាចនាំឱ្យមានការតំលើងអត្រាការប្រាក់នៅ US ។

In November, the Singapore dollar slid against the US greenback, depreciating to 1.699 from 1.691 in October. The Thai baht also slightly weakened against the US dollar, trading at 41.08, a 0.5 percent depreciation from a month earlier. Asian currencies gave up some ground after the dollar was boosted by strong US growth data that pointed to more increases in US interest rates.

## Thai Baht and Singaporean Dollar Against the US Dollar




*Note: Data are up to 28 November 2005.*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែតុលា ថ្លៃអង្ករអន្តរជាតិកើនយ៉ាងខ្លាំងដោយសារកង្វះអង្ករនាំចេញ ។ និន្នាការនេះប្រហែលបន្តរហូតដល់ ផលស្រូវថ្មីរបស់អាស៊ីចូលដល់ទីផ្សារនៅចុងឆ្នាំ ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) កើនដល់ ១១៩ រឺកើន ៣,៣លេខ ធៀបនឹងខែមុន ។ នៅ US ថ្លៃអង្ករស្ទុះដល់ ៣០៣ដុល្លារ/តោន ធៀបនឹង ២៨១ដុល្លារ/តោននៅខែកញ្ញា ។ អង្ករ Thai 100 percent B លក់ថ្លៃ ២៩២ដុល្លារ/តោននៅខែតុលា ធៀបនឹង ២៩០ដុល្លារ/តោន នៅខែកញ្ញា ។

In October, world rice prices rose strongly due to a shortage of export supplies. This trend is likely to continue until the new Asian harvest reaches markets at the end of the year. The international prices index (IPO) rose by 3.3 points from the previous month to 119 in October. Rice prices in the US jumped from $281 per ton in September to $303 per ton in October. In Thailand, prices rose slightly in October. Thai 100 percent B was at $292 per ton in October, against $290 per ton in September.

**International Prices Index and Export Rice Prices** (US$/ton FOB)




Sources: Osiriz/InfoArroz and InterRice.

នាខែវិច្ឆិកា សណ្តែកសៀងឡើងថ្លៃ ឯពោតចុះថ្លៃ ។ សណ្តែកសៀងលក់បាន ២៣១,៤៦ដុល្លារ/តោននៅខែវិច្ឆិកា ធៀបនិង ២២៥,១៩ដុល្លារ/តោននៅខែតុលា រឺឡើងថ្លៃ ៣% ។ ពោតចុះថ្លៃដល់ ៩៥,៦៧ដុល្លារ/តោននៅខែវិច្ឆិកា រឺចុះថ្លៃ ៦%ធៀបនឹងខែតុលា (១០១,៥២ដុល្លារ/តោន) ។ ប្រេងឆាឡើងថ្លៃបន្តិច ដល់ ៤២២ដុល្លារ/តោននៅខែតុលា ធៀបនិង ៤២១ដុល្លារ/តោននៅខែកញ្ញា ។

In November, the price of soybean rose, while the price of maize went down. Soybeans sold at US$231.46 per ton in November against $225.19 in October a 3 percent increase. The price of maize in November decreased by 6 percent from $101.52 per ton in October to $95.67 per ton in November. The price of palm oil rose slightly, to $422 per ton in October, up from $421 in September.

**International Prices of Soybean, Maize and Palm Oil** (US$/ton FOB)




Source: Food and Agriculture Organisation (FAO)

នៅខែវិច្ឆិកា ប្រេងឆៅចុះថ្លៃ ប៉ុន្តែសាំងឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃនៃប្រទេសសមាជិក OPEC គឺ ៥១,៧២ដុល្លារ/ធុង រឺចុះថ្លៃ ៥% ធៀបនិងខែមុន ។ សាំងធម្មតានៅ US Gulf Coast ឡើងថ្លៃដល់ ៥៨,៤៩សេន/លីត្រ រឺ ឡើងថ្លៃ ២៣%ធៀបនឹងខែតុលា (៤៧,៥១សេន/លីត្រ) ។

In November, the price of crude oil declined, while the price of gasoline rose. The OPEC countries spot price of crude oil was US$51.72 per barrel, a 5 percent decrease from the previous month. Regular gasoline on the US Gulf Coast rose by 23 percent from the previous month, selling at 58.49 cents per litre, against 47.51 cents per litre in October.

**Prices of Crude Oil and Gasoline**




***Note: Data are up to 30 October** 2005.*
Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច / Economic News

**គំរោងវិនិយោគនៅកម្ពុជា កើនខ្ពស់បំផុតនៅឆ្នាំ២០០៥:** ការអនុមតិវិនិយោគទុនថ្មីៗនៅកម្ពុជា បន្តកើនល្បឿនបំផុតនៅឆ្នាំ២០០៥ ។ តាមរបាយការណ៍ដំបូងមួយ គំរោងវិនិយោគដែលត្រូវបានអនុម័តរហូតដល់ចុងខែតុលា មានជិតដល់ ១ពាន់លានដុល្លារ គិតជាទ្រព្យសកម្មជាប់លាប់ ។ CDC បានអនុម័តមិនទាន់ជាផ្លូវការនូវវិនិយោគ ៩៧៦លានដុល្លារ ក្នុងនេះ ៦២១ លានដុល្លារ ជាវិនិយោគផ្ទាល់ពីបរទេស ។ វិនិយោគទាំងនេះមានសក្តានុពលផ្តល់ការងារ ៨២.៣៥០ ។ នៅឆ្នាំ២០០៤ មានការអនុមតិគំរោងវិនិយោគ ២១៦លានដុល្លារ ក្នុងនេះវិនិយោគផ្ទាល់ពីបរទេសមាន ១៤១លានដុល្លារ ។ នៅឆ្នាំ២០០៣ វិនិយោគផ្ទាល់ពីបរទេសមាន ៦៣លានដុល្លារ នៅ ២០០២ គឺ ១៤៥លានដុល្លារ និង ២០០១ គឺ ១៤០លានដុល្លារ ។ ក្នុងរបាយការណ៍នៅខែតុលា ចិននៅតែជាអ្នកវិនិយោគធំជាគេដល់ ៤៤២លានដុល្លារ បន្ទាប់មក ថៃ៦៦លានដុល្លារ និងតៃវ៉ាន់៤១លានដុល្លារ ។ ក្នុងឆ្នាំនេះមានការវិនិយោគលើ ១៤រោងចក្រកាត់ដេរ ដែលបង្ហាញពីកំនើនទំនុកចិត្តក្នុងវិស័យនេះ ព្រោះកាលពីមួយឆ្នាំមុន មានការបារម្ភពីរឿងអស់កូតា ។

***Cambodia's proposed investment reaches all-time high in 2005:*** Approvals of new business investment in Cambodia have continued at a record pace in 2005. A preliminary report on investment through October 31 shows approvals for projects approaching US$1 billion in fixed assets. According to the Council for the Development of Cambodia (CDC), it has unofficially approved $976 million worth of investments, with $621 million of that coming as foreign direct investment. The potential job creation from these investments is pegged at 82,350. In 2004, $216 million worth of investment projects were approved, involving $141 million in foreign direct investment. In 2003, FDI was $63 million; in 2002 it stood at $145 million and in 2001 $140 million. In the October report, China remains the top investor with $442 million, followed by Thailand with $66 million and China's Taiwan with $41 million. The report lists 14 garment factory investments this year, a sign of increased confidence in an industry that one year ago contemplated the end of worldwide garment quotas with dread. An official said 19 of the investments are expansions. *(Cited from Xinhua, 3 December 2005)*

**ក្រុងសេអ៊ូលនឹងចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយអាស៊ាន:** កូរ៉េខាងត្បូងរំពឹងថា នឹងចុះកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយអាស៊ាននៅពាក់កណ្តាលខែធ្នូ ។ ក្រសួងពាណិជ្ជកម្ម និងក្រសួងការបរទេសនិយាយថា កិច្ចព្រមព្រៀងនឹងចុះហត្ថលេខានៅពេលប្រធានាធិបតី Roh Moo-hyun មកចូលរួមកិច្ចប្រជុំអាស៊ាន+៣ នៅក្រុងកូឡាឡាំពួ ម៉ាឡេស៊ី នៅថ្ងៃ ១២ ធ្នូ ។ កិច្ចព្រមព្រៀងនេះជាក្របខ័ណ្ឌមូលដ្ឋាន សំរាប់តំបន់ពាណិជ្ជកម្មសេរីផ្លូវការ ហើយនឹងមានបញ្ជាក់គ្រួសៗពីវិសាលភាព និងតារាងពេលនៃការកាត់បន្ថយពន្ធគយ ។ បន្ទាប់មក ភាគីទាំងពីរត្រូវកំនត់ចំនុចលំអិតដូចជា បញ្ជីមុខទំនិញមិនត្រូវធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ។ កិច្ចព្រមព្រៀងនេះមានគោលដៅធ្វើសេរីភាវូបនីយកម្មលើទំនិញ ៩០% នៅឆ្នាំ២០១០ ។

***Seoul to Sign Trade Deal with ASEAN:*** South Korea is expected to sign a framework agreement for free trade with the Association of South-East Asian Nations in mid-December. The Foreign Affairs and Trade Ministry says the accord will be signed when President Roh Moo-hyun attends the ASEAN plus three summit in Kuala Lumpur, Malaysia, beginning December 12. The agreement is a basic framework for a formal FTA that's expected in the fist half of next year and roughly outlines the scope and timetable of tariff reductions. Both sides still need to finalise details such as the list of products that will be exempt from trade liberalisation. The South Korea-ASEAN FTA aims to liberalise 90 percent of traded goods by 2010. *(Cited from Arirang News, 30 November 2005)*

**សហរដ្ឋអាមេរិក និងអាស៊ាន ឯកភាពរិតចំណងទាក់ទង:** សហរដ្ឋអាមេរិក និងអាស៊ាន បានធ្វើសេចក្តីប្រកាសរួមពីការបង្កើនភាពជាដៃគូ លើបញ្ហាសន្តិសុខ សេដ្ឋកិច្ច សង្គមកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្ស ។ រដ្ឋមន្ត្រីការបរទេសថៃលើកថា ភាពជាដៃគូនេះ ដែលគេហៅថា ក្របខ័ណ្ឌពាណិជ្ជកម្ម និងវិនិយោគអាស៊ាន-US អាចនាំទៅរកកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីរវាងសមាជិកទាំង១០ និង US ។ US បានចុះហត្ថលេខារួចហើយ លើកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីទ្វេភាគីជាមួយសិង្ហបូរី និងកំពុងចរចាជាមួយថៃពីកិច្ចព្រមព្រៀងពាណិជ្ជកម្ម ។ បន្ថែមលើបញ្ហាសេដ្ឋកិច្ច សេចក្តីប្រកាសរួម អំពាវនាវឱ្យបង្កើនសហប្រតិបត្តិការប្រយុទ្ធនឹងឧក្រិដ្ឋកម្មឆ្លងដែន ដូចជា អំពើភាវរកម្ម ការសាយភាយអាវុធមហាប្រល័យ ចរាចរឱសថខុសច្បាប់ ព្រមទាំងពង្រឹងសន្តិសុខព្រំដែនគោក និងព្រំដែនទឹក ។

***US and ASEAN agree on stronger links:*** The United States and ASEAN members issued a joint statement calling for an "enhanced partnership" on security, economic, social and human development issues. Kantathi Suphamongkhon, the Thai foreign minister, said the partnership, known as the Asean-US Trade and Investment Framework, could lead to a regional free trade area agreement between the 10 members and the US. The US has already signed a bilateral free trade area agreement with Singapore and is in talks with Thailand over a trade treaty. ASEAN members hope that the cooperation will reaffirm US engagement in south-east Asia. In addition to economic issues, the statement calls for closer cooperation in combating transactional crimes, including terrorism, halting the proliferation of weapons of mass destruction, clamping down on illegal drug trafficking and enhancing maritime and border security. *(Cited from Bangkok Post, 18 November 2005).*